General permission to publish and disclose information

# ការអនុញ្ញាតទូទៅដើម្បីបោះពុម្ពផ្សាយ និងលាតត្រដាងព័ត៌មាន

សូមគោរពឪពុកម្ដាយ/អ្នកថែទាំ

ខ្ញុំកំពុងស្វែងរកអនុញ្ញាតពីអ្នក ដើម្បីយល់ព្រមឱ្យសាលារៀន/ក្រសួងអប់រំដើម្បីបោះពុម្ពផ្សាយ និង/ឬលាតត្រដាងព័ត៌មានអំពីកូនរបស់អ្នក ក្នុងគោលបំណងចែករំលែកបទពិសោធន៍របស់ពួកគេជាមួយសិស្សដទៃទៀត ជូនដំណឹងដល់សាលារៀន និងសហគមន៍ទូលំទូលាយ អំពីសាលារៀន សកម្មភាពសិស្ស និងការថតសិស្សកំពុងចូលរួមនៅក្នុងគម្រោងសំខាន់ៗ ឬសេវាកម្មសហគមន៍។

ព័ត៌មាននេះអាចរួមមានឈ្មោះកូនរបស់អ្នក អាយុ ថ្នាក់រៀន និងព័ត៌មានដែលប្រមូលបាននៅសាលារៀនដូចជារូបថត សំឡេង និងរូបភាពមើលឃើញដែលថតជាប់កូនរបស់អ្នក កិច្ចការ និងការបញ្ចេញមតិនានារបស់កូនអ្នក ដូចជានៅក្នុងប្រព័ន្ធផ្សព្វផ្សាយអន្តរកម្ម។

ការប្រាស្រ័យទាក់ទងដែលព័ត៌មានរបស់កូនអ្នកអាចត្រូវបានបោះពុម្ព ឬលាតត្រដាង ប៉ុន្តែអាចមានលើសពីនេះ៖

- គេហទំព័រសាធារណៈរបស់ក្រសួងអប់រំ រួមទាំងគេហទំព័ររបស់សាលារៀន អ៊ីនត្រាណែតរបស់ក្រសួងអប់រំ (សម្រាប់តែបុគ្គលិកប៉ុណ្ណោះ), blogs (ប្លក់) និង wikis (វិគី)
- ការបោះពុម្ពផ្សាយរបស់ក្រសួងអប់រំ រួមទាំងព្រឹត្តិបត្រសាលា ទស្សនាវដ្ដីសាលាប្រចាំឆ្នាំ និងរបាយការណ៍សិក្សា សម្ភារៈផ្សព្វផ្សាយដែលត្រូវបានបោះពុម្ព និងផ្សព្វផ្សាយជាអេឡិចត្រូនិក រួមទាំងនៅលើគេហទំព័ររបស់ក្រសួង។
- គណនីប្រព័ន្ធផ្សព្វផ្សាយសង្គមផ្លូវការរបស់ក្រសួង និងសាលារៀន នៅលើបណ្ដាញនានាដូចជា YouTube (យូធូប), Facebook (ហ្វេសប៊ុក) និង Twitter (ធ្វីតធើរ)
- សារព័ត៌មានមូលដ្ឋាន និងទីក្រុងធំៗ និងទស្សនាវដ្ដី ហើយនិងប្រព័ន្ធផ្សព្វផ្សាយដទៃទៀត។

ឪពុកម្ដាយគួរយល់ដឹងថា នៅពេលដែលព័ត៌មានត្រូវបានបោះពុម្ពផ្សាយនៅលើគេហទំព័រសាធារណៈ និងបណ្ដាញប្រព័ន្ធផ្សព្វផ្សាយសង្គម គេអាចរកឃើញវានៅតាមអនឡាញក្នុងរយៈពេលជាច្រើនឆ្នាំ ប្រសិនបើមិនជាអចិន្ត្រៃយ៍ទេនោះ។ កម្មវិធីស្វែងរកក៏អាចលាក់ទុក ឬរក្សាទុកច្បាប់ចម្លងនៃព័ត៌មានដែលបានបោះពុម្ពផ្សាយផងដែរ។ ព័ត៌មានដែលបានបោះពុម្ពផ្សាយក៏អាចត្រូវបានដាក់ភ្ជាប់ដោយភាគីទីបីផងដែរ។

សូមបំពេញទម្រង់បែបបទអនុញ្ញាត ហើយប្រគល់ឱ្យសាលារៀនវិញត្រឹមកាលបរិច្ឆេទខាងក្រោម៖

Date for return of permission form

**ជំនួយអ្នកបកប្រែផ្ទាល់មាត់**

ប្រសិនបើអ្នកចង់បានព័ត៌មានបន្ថែម សូមទាក់ទងមកសាលារៀន។

ប្រសិនបើអ្នកត្រូវការជំនួយអ្នកបកប្រែផ្ទាល់មាត់ដើម្បីទាក់ទងមកសាលារៀន សូមហៅទូរសព្ទលេខ 131 450 ដោយប្រាប់ការីទូរសព្ទនូវភាសាដែលអ្នកត្រូវការ ហើយស្នើសុំឱ្យពួកគេទូរសព្ទទៅសាលារៀន។ ពេលនោះការីទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទដើម្បីជួយក្នុងការសន្ទនារបស់អ្នក។ អ្នកនឹងមិនត្រូវគេគិតថ្លៃសម្រាប់សេវាកម្មនេះទេ។

ដោយក្ដីគោរព

ឈ្មោះនាយកសាលា (Name of principal)

ឈ្មោះសាលារៀន (Name of school)

# ការយល់ព្រមផ្តល់ការអនុញ្ញាតដល់ឪពុកម្តាយ/អ្នកថែទាំ ដើម្បីបោះពុម្ពផ្សាយ
# Parent/carer permission to publish consent

ខ្ញុំបានអានការអនុញ្ញាតនេះ ដើម្បីបោះពុម្ពផ្សាយ និង៖

(គូសយកតែប្រអប់មួយខាងក្រោមនេះប៉ុណ្ណោះ ហើយទុកប្រអប់មួយទៀតឱ្យនៅទទេ)

☐ ខ្ញុំអនុញ្ញាតឱ្យសាលារៀន/ក្រសួងអប់រំ បោះពុម្ពផ្សាយព័ត៌មានអំពីកូនរបស់ខ្ញុំដូចបានរៀបរាប់ខាងលើ រួមទាំងនៅក្នុងការប្រាស្រ័យទាក់ទងដែលអាចចូលប្រើប្រាស់បានជាសាធារណៈ។
I give permission to the school/Department of Education to publish information about my child as described above, including in publicly accessible communications.

☐ ខ្ញុំមិនអនុញ្ញាតឱ្យសាលារៀន/ក្រសួងអប់រំ បោះពុម្ពផ្សាយព័ត៌មានអំពីកូនរបស់ខ្ញុំដូចបានរៀបរាប់ខាងលើនេះទេ រួមទាំងនៅក្នុងការប្រាស្រ័យទាក់ទងដែលអាចចូលប្រើប្រាស់បានជាសាធារណៈ។
I do not give permission to the school/Department of Education to publish information about my child as described above, including in publicly accessible communications.

ការអនុញ្ញាតដែលបានចុះហត្ថលេខានេះនៅតែមានប្រសិទ្ធភាព រហូតដល់ខ្ញុំជូនដំណឹងដល់សាលារៀនផ្សេងពីនេះ។

ឈ្មោះកូន (សូមសរសេរជាអក្សរពុម្ព) ______________________________
Name of child

ឈ្មោះឪពុកម្តាយ / អ្នកថែទាំ (សូមសរសេរជាអក្សរពុម្ព) ______________________________
Name of parent/carer

ហត្ថលេខារបស់ឪពុកម្តាយ / អ្នកថែទាំ ______________________________
Signature of parent/carer

កាលបរិច្ឆេទ ______________________________
Date